ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

## និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ  លោកជំទាវ ឧត្តមសេនីយ៍ឯក បណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពី ការរៀបចំសិក្ខាសាលាថ្នាក់ជាតិ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ៥ឆ្នាំ(២០២៤-២០២៨) បន្ត។

ថ្ងៃអង្គារ-ព្រហស្បតិ៍ ១០-១២រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៥-០៧ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៨:០០ នាទីព្រឹក នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលាស្តីពី ការប្រមូលធាតុចូល ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ៥ឆ្នាំ (២០២៤-២០២៨) បន្ត រយៈពេលបីថ្ងៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។**

### I. សមាសភាពចូលរួម

- **ឯកឧត្តម លោកជំទាវ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- **ឯកឧត្តម លោកជំទាវ** រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មកពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- **លោកប្រធាន អនុប្រធាន** នាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- **លោកប្រធាន អនុប្រធាន** នាយកដ្ឋាន មកពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- **តំណាងអង្គការដៃគូពាក់ព័ន្ធ និងមន្ត្រីបច្ចេកទេស** សរុបចំនួន **១៦១**រូប ស្រី**៦២**រូប។

### II. ទស្សនៈវិស័យ គោលដៅ និងគោលបំណង

**<u>ទស្សនៈវិស័យ</u>**

“ព្រះរាជាណាចក្រកម្ពុជា មានសន្តិភាព សមភាព យុត្តិធម៌ និងការអភិវឌ្ឍ ប្រកបដោយសក្តានុពលនៃមូលធនមនុស្ស ដោយគ្មានអំពើជួញដូរ កេងប្រវ័ញ្ចគ្រប់ទំរង់លើមនុស្ស ទាំងនៅក្នុងប្រទេសកម្ពុជា និងនៅក្រៅប្រទេស”

**<u>គោលដៅ</u>** លុបបំបាត់រាល់ទម្រង់ចាស់ថ្មីនៃអំពើជួញដូរមនុស្ស ដែលបង្កភាពរងគ្រោះដោយការធ្វើសកម្មភាពតាមគ្រប់មធ្យោបាយ ក្នុងគោលបំណងកេងប្រវ័ញ្ចដោយទុច្ចរិត ធ្វើឲ្យមនុស្សរងគ្រោះយ៉ាងធ្ងន់ធ្ងរដល់រូបកាយ សុខភាពផ្លូវចិត្ត ផ្លូវភេទ ដែលជាការរំលោភសិទ្ធិ អាយុជីវិត និងផលប្រយោជន៍ស្របច្បាប់ របស់មនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ស្ថានភាព គ្រប់ព៌ណសម្បុរ ក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងលើប្រជាជនកម្ពុជា នៅក្រៅប្រទេស។

**គោលបំណង** ជានាឱ្យមានប្រព័ន្ធសុវត្ថិភាពសង្គម ដើម្បីការបង្ការទប់ស្កាត់ភាពរងគ្រោះឱ្យមានប្រសិទ្ធភាព ការអនុវត្តច្បាប់ដែលមានឥទ្ធិពល និងការផ្តន្ទាទោស យ៉ាងសុក្រឹត្យចំពោះបទឧក្រិដ្ឋនេះ ដើម្បីយុត្តិធម៌សង្គម ជាពិសេសការការពារសិទ្ធិ ផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលជាមនុស្សគ្រប់វ័យ គ្រប់ភេទ គ្រប់ព័ណសម្បុរ និងនៅគ្រប់ស្ថានភាពក្នុងសង្គម។

- លោក **អៀង ម៉ុនថន** ទីប្រឹក្សាបច្ចេក គ.ជ.ប.ជ បានឡើងធ្វើបទបង្ហាញពីរបាយការណ៍វាយតម្លៃ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំបន្ត ដោយសង្ខេបពីលទ្ធផលបឋម បញ្ហាប្រឈម និងអនុសាសន៍ផ្សេងៗ ដោយយកពីក្នុងយុទ្ធសាស្ត្រទាំង៤ នៃផែនការយុទ្ធសាស្ត្រជាតិ។
- ជាកិច្ចបន្ទាប់ **លោកជំទាវ** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំកិច្ចពិភាក្សាដោយផ្ទាល់ ទៅលើយុទ្ធសាស្ត្រដែលនៅសេសសល់ទាំងបី។ បន្ទាប់ពីបានពិនិត្យជជែក ពិភាក្សា កែសម្រួល ផ្តល់នូវធាតុចូលទៅលើចង្កោមសកម្មភាពត្រូវអនុវត្ត ដោយមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូ រួចមក អង្គសិក្ខាសាលាសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

## III. លទ្ធផលសម្រេចបាន

- **យុទ្ធសាស្ត្រទី២៖ លើកកម្ពស់ការបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទលើកុមារ**

<u>ចង្កោមសកម្មភាព</u>

- រៀបចំ និងអនុវត្តវិធីសាស្ត្រ ឆ្ពោះទៅការផ្លាស់ប្តូរឥរិយាបថអវិជ្ជមានដែលងាយបង្កភាពរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់
- លើកកម្ពស់ការធ្វើការសម្រេចចិត្ត ដើម្បីជម្រើសដែលល្អប្រសើរសម្រាប់ការទទួលបានការងារ និងមុខរបរសមរម្យ
- លើកកម្ពស់ការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់
- ពង្រឹងកិច្ចសហប្រតិបត្តិការ និងវិធានការគ្រប់គ្រងព្រំដែនរួមគ្នា
- វិធានការធ្វើអធិការកិច្ច ទីតាំងគោលដៅសង្ស័យពាក់ព័ន្ធអំពើជួញដូរមនុស្ស និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- លើកកម្ពស់សមត្ថភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសារ (ការបណ្តុះបណ្តាលជំនាញគ្រប់គ្រងផ្នែកហិរញ្ញវត្ថុគ្រួសារ ផែនការជីវិត ជំនាញបំណិនជីវិត/ជំនាញទន់ និងភាពធន់ទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ...)
- ជំរុញការចូលរួមពីវិស័យឯកជនក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ (វិស័យអប់រំ ទេសចរណ៍ ការងារ កសិកម្ម ឧស្សាហកម្ម សិប្បកម្ម សុខាភិបាល មីក្រូហិរញ្ញវត្ថុ ធនាគារ ប្រៃសណីយ៍ និងទូរគមនាគមន៍...)
- វិធានការបង្ការទប់ស្កាត់ តាមរយៈការបង្កើនការយល់ដឹងអំពីច្បាប់ គោលនយោបាយ លិខិតូបករណ៍ និងបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធរាល់ទម្រង់នៃបទល្មើសជួញដូរមនុស្ស
- ពង្រឹងការអនុវត្តវិធានការបង្ការទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ ឬការជ្រើសរើសគូស្រករ រវាងពលរដ្ឋខ្មែរ និង ជនបរទេស
- ជំរុញការអនុវត្តវិធានការបង្ការទប់ស្កាត់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងដល់អ្នកសារព័ត៌មាន
- ពង្រឹងប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈ
- ពង្រឹង និងជំរុញការប្រើប្រាស់យន្តការរាយការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលា

- ជំរុញការអនុវត្តវិធានការបង្ការទប់ស្កាត់របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងដល់អ្នកសារព័ត៌មានពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ
- ពង្រឹងប្រសិទ្ធភាព វិសាលភាព និងគុណភាពនៃយុទ្ធនាការអប់រំផ្សព្វផ្សាយជាសាធារណៈដើម្បីបង្ការទប់ស្កាត់ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារ
- លើកកម្ពស់ប្រព័ន្ធសុវត្ថិភាពកុមារនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនពីអំពើជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារគ្រប់រូបភាព (មុខវិជ្ជាអប់រំសុខភាពសិក្សា)
- ពង្រឹង និងជំរុញការប្រើប្រាស់យន្តការរាយការណ៍ ដើម្បីឆ្លើយតបទាន់ពេលវេលា
- លើកកម្ពស់សុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ
- ជំរុញការអនុវត្តវិធានការពាក់ព័ន្ធនឹងកិច្ចការពារកុមារ (កម្មវិធីកុមារឆ្លាតវៃ និងសុវត្ថិភាពឌីជីថល-និយ័តករក្រសួងប្រៃសណីយ៍)
- ជំរុញការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពី ប្រព័ន្ធកិច្ចការពារកុមារ (ក្រុមប្រឹក្សាជាតិដើម្បីកុមារ)

▪ **យុទ្ធសាស្ត្រទី៣៖ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**

**<u>លទ្ធផលរំពឹងទុក</u>**

- ពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់
- ចង់ឱ្យមានកិច្ចសហការរវាងជនរងគ្រោះ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឱ្យជនរងគ្រោះចូលរួមក្នុងដំណើរការនីតិវិធីតុលាការ
- ចង់ឱ្យមានការទទួលស្គាល់ពីសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះ និងតួនាទីរបស់ស្ថាប័នពាក់ព័ន្ធក្នុងដំណើរការនីតិវិធីតុលាការ
- ចង់ឱ្យមានកិច្ចប្រជុំជាទៀងទាត់រវាងស្ថាប័នពាក់ព័ន្ធ (សមត្ថកិច្ច និងអង្គការដៃគូ) អាចបញ្ចូលទៅក្នុងសកម្មភាព
- ទទួលបានគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដើម្បីទទួលបានជំនឿ ទំនុកចិត្តពីប្រជាពលរដ្ឋ
- រយៈពេលសរុបក្នុងការជំនុំជម្រះក្តីមានការថយចុះ
- ប្រសិទ្ធភាពក្នុងការជំនុំជម្រះក្តីមានភាពប្រសើរជាងមុន

**<u>ចង្កោមសកម្មភាព</u>**

- ជំរុញការសិក្សាស្រាវជ្រាវ ភាពប្រែប្រួលនៃបទល្មើស ជាពិសេសពាក់ព័ន្ធនឹងបទល្មើសបច្ចេកវិទ្យា
- បង្កើនការប្រមូលព័ត៌មានពីប្រភពផ្សេងៗ ដើម្បីបើកការស៊ើបអង្កេត បង្ក្រាប និងផ្តន្ទាទោសជនល្មើស និងអ្នកពាក់ព័ន្ធអំពើជួញដូរមនុស្ស
- ពង្រឹងកិច្ចសហការរវាងស្ថាប័នជំនាញអនុវត្តច្បាប់ និងស្ថាប័នពាក់ព័ន្ធ នៅក្នុងប្រទេស និងក្រៅប្រទេស និងកិច្ចសហការជាមួយមន្ត្រីជំនាញនៃប្រទេសកម្ពុជា និងមន្ត្រីជំនាញនៃប្រទេសពាក់ព័ន្ធ ដើម្បីសិទ្ធិ និងឧត្តមប្រយោជន៍ជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស ។
- ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ អំពីជំនាញប្រតិបត្តិការ លើការងារប្រឆាំងការជួញដូរមនុស្ស
- ពង្រឹងកិច្ចប្រតិបត្តិការក្នុងការអនុវត្តច្បាប់ បទដ្ឋានគតិយុត្តិ អនុស្សរណៈ កិច្ចព្រមព្រៀង ស្តង់ដានីតិវិធីប្រតិបត្តិ រវាងប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ
- ពិនិត្យឡើងវិញ កែសម្រួល ឬធ្វើវិសោធនកម្មមាត្រាពាក់ព័ន្ធក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទម្រង់។

- យុទ្ធសាស្ត្រទី៤៖ បង្កើនកិច្ចការពារជនរងគ្រោះ (ពិសេស ស្ត្រី និងកុមារ)

<u>**លទ្ធផលរំពឹងទុក**</u>

ក្រោយទទួលបានកិច្ចគាំពារ ជនដែលធ្លាប់រងគ្រោះ (គ្រប់វ័យ គ្រប់ភេទ គ្រប់ពូជសាសន៍ ព៌ណសម្បុរ គ្រប់ស្ថានភាព គ្រប់ទីតាំងភូមិសាស្ត្រ) បានរស់នៅដោយកក់ក្ដៅក្នុងគ្រួសារ ឬសហគមន៍ ប្រកបដោយសេចក្ដីថ្លៃថ្នូរ ទទួលបានសេវាសាធារណៈ និងសេវាដទៃទៀត រួមទាំងជំនាញវិជ្ជាជីវៈ បំណិនជីវិត ព្រមទាំងឱកាសទទួលបាននូវផលប្រយោជន៍ក្នុងការងារ និងមុខរបរប្រកបដោយបរិយាប័ន្ន និងគ្មានការរើសអើង។ ផ្អែកលើលទ្ធផលរំពឹងទុក យើងបានកែសម្រួលពាក្យពេចន៍ ឃ្លាឃ្លោង និងបន្ថែមធាតុចូលនៃចង្កោមសកម្មភាពដូចខាងក្រោម៖

- ពង្រឹងការអនុវត្តគោលការណ៍នៃការកំណត់អត្តសញ្ញាណ ដោយផ្ដោតការយកចិត្តទុកដាក់លើលក្ខណៈដោយឡែក ឬស្ថានភាពដោយឡែកៗពីគ្នា មានជាអាទិ៍ កុមារ ស្ត្រីវ័យក្មេង ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនចាស់ជរា អ្នកមានពិការភាព ភាពខុសគ្នានៃយេនឌ័រ ជាដើម
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្ដល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលឱ្យកាន់តែប្រសើរ ដើម្បីលើកកម្ពស់ កិច្ចការពារជនរងគ្រោះ គ្រប់ដំណាក់កាល
- បង្កើតគោលការណ៍បំពេញបន្ថែមសម្រាប់ការអនុវត្តវិធីសាស្ត្រផ្ដល់កិច្ចគាំពារ ដោយផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើក្រុមគោលដៅជាអាទិភាព មានជាអាទិ៍ ក្រុមស្ត្រី ក្រុមយុវវ័យ ក្រុមជនមានពិការភាព យេនឌ័រ ជនដែលមានជំនឿសាសនា និងភាសាដោយឡែក ជាដើម
- ពង្រឹងប្រសិទ្ធភាព និងគុណភាពការស្ដារនីតិសម្បទាជនរងគ្រោះ ដោយផ្ដោតការយកចិត្តទុកដាក់លើលក្ខណៈដោយឡែក ឬស្ថានភាពដោយឡែកៗពីគ្នា មានជាអាទិ៍ កុមារ ស្ត្រីវ័យក្មេង ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនចាស់ជរា អ្នកមានពិការភាព ភាពខុសគ្នានៃយេនឌ័រ ជាដើម
- ពង្រឹងសមត្ថភាព តួនាទី ទំនួលខុសត្រូវ និងក្រមសីលធ៌មវិជ្ជាជីវៈ ឥរិយាបទគោរពសិទ្ធមនុស្ស សិទ្ធិស្ត្រី សិទ្ធិកុមារ ដល់មន្ត្រីមូលដ្ឋានជួរមុខ
- ពង្រឹងសមត្ថភាពអ្នកធ្លាប់រងគ្រោះដោយអំពើជួញដូរមនុស្សឱ្យក្លាយជាជនបង្គោល ឬភ្នាក់ងារនៃការផ្លាស់ប្ដូរជាវិជ្ជមាននៅក្នុងសហគមន៍ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដោយគ្មានការរើសអើងវ័យ ភេទ ពូជសាសន៍ ព៌ណសម្បុរ ពិការភាព ទីតាំងភូមិសាស្ត្រ និងស្ថានភាពឯទៀតឡើយ
- លើកកម្ពស់ការផ្សព្វផ្សាយអំពីការផ្ដល់សេវា តាមប្រព័ន្ធឌីជីថល (រួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពជាទៀងទាត់នៃបញ្ជីសេវា regular service mapping/update) និងកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពជាប្រចាំអំពីសេវាដែលផ្ដល់ដោយអង្គការមិនមែនរដ្ឋាភិបាល ដល់ជនងាយរងគ្រោះ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដោយផ្ដោតលើចរិតលក្ខណៈនៃភាពរងគ្រោះ ដោយឡែកៗពីគ្នា មានជាអាទិ៍ លើស្ត្រី កុមារ ជនមានពិការភាព
- លើកកម្ពស់ការយល់ដឹងរបស់គ្រួសារ និងប្រជាជននៅក្នុងសហគមន៍ ដើម្បីកាត់បន្ថយការរើសអើងអ្នកធ្លាប់រងគ្រោះដោយអំពើជួញដូរមនុស្សដែលមករស់នៅជាមួយ
- លើកកម្ពស់ការយល់ដឹងរបស់ជនរងគ្រោះ គ្រួសារ និងសហគមន៍អំពីសេវា និងនីតិវិធីដើម្បីទទួលបានសេវាគាំពារជនរងគ្រោះ
- ពង្រឹងសមត្ថភាពអ្នកផ្ដល់សេវាកម្មដល់ជនរងគ្រោះ គុណភាព និងប្រសិទ្ធភាពនៃសេវាកម្ម ដោយផ្ដោតលើតម្រូវការចាំបាច់ និងប្រភេទនៃអ្នកទទួលសេវា

## IV. សន្និដ្ឋាន និងសំណូមពរ

**លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានលើកឡើងថា ផែនការនេះ មិនមែនជាផែនការសកម្មភាពធម្មតាទេ វាជាផែនការយុទ្ធសាស្ត្រ៥ឆ្នាំ សុំឱ្យមានការគិតស៊ីជម្រៅបន្តិចទៅលើកិច្ចការនេះ។ បន្ទាប់ពីធ្វើសេចក្តីព្រាងហើយ លោកជំទាវសុំឱ្យបណ្តាក្រសួង ស្ថាប័ន សាកល្បងទាញចេញនូវបណ្តាសកម្មភាព ដោយបង្កើតជាសៀវភៅស្តើងមួយ ហើយកត់ត្រាចូលសកម្មភាពដែលជាចង្កោមសកម្មភាពសំខាន់ៗតែប៉ុណ្ណោះ ដែរចង្កោមសកម្មភាពទាំងនោះ នឹងធ្វើឱ្យសម្រេចលទ្ធផលរំពឹងទុកនៃយុទ្ធសាស្ត្រមួយ ហើយលទ្ធផលរំពឹងទុក នៃយុទ្ធសាស្ត្រទាំងអស់ នឹងឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកនៃផែនការយុទ្ធសាស្ត្ររយៈ៥ឆ្នាំ ហើយតួអង្គសំខាន់គឺនគរបាលយុត្តិធម៌ ក្រសួងយុត្តិធម៌ និងស្ថាប័នអយ្យការ។ **លោកជំទាវ** ក៏បានស្នើសុំឱ្យក្រសួង ស្ថាប័ន និងអង្គការដៃគូ មានការពិនិត្យឡើងវិញរាល់សកម្មភាពទាំងអស់ ហើយរៀបចំសកម្មភាពឱ្យមានលក្ខណៈជាប្រព័ន្ធ ដើម្បីងាយស្រួលតាមដាន ត្រួតពិនិត្យ រយៈពេល០៥ឆ្នាំបន្តទៅមុខ តើនៅខ្វះខាតបំណុចណា ចង់កែលម្អចំណុចណា បើកាលណាយើងដាក់សកម្មភាពធំពេកក្រែងធ្វើមិនអស់។

**<u>សំណូមពរ៖</u>**

- ផ្លាស់ប្តូរចំណងជើងយុទ្ធសាស្ត្រទី៣ «លើកកម្ពស់ការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទំរង់» ទៅជា «ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សគ្រប់ទំរង់»
- ពិនិត្យ កែសម្រួល ឬធ្វើវិសោធនកម្មមាត្រាពាក់ព័ន្ធក្នុងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីដោះស្រាយបញ្ហាពលកម្មដោយបង្ខំ ការបង្ខំឱ្យប្រព្រឹត្តិបទល្មើស (បន្ថែម ឬកែលម្អមាត្រាពាក់ព័ន្ធដើម្បីបញ្ចូលចំណុច/មាត្រាពាក់ព័ន្ធនឹងការជួញដូរទារក បទល្មើសជួញដូរមនុស្សតាមប្រព័ន្ធឌីជីថល)
- បង្កើតមូលនិធិសម្រាប់ជួយគាំទ្រដល់ជនរងគ្រោះ (អាចពិចារណាដាក់បញ្ចូលទៅក្នុងសកម្មភាព)
- ជំរុញឱ្យមានការចូលរួមពីវិស័យឯកជនក្នុងកិច្ចសហការ និងសម្របសម្រួលដល់ ដំណើរការស៊ើបអង្កេត និងបង្ក្រាបបទល្មើសជួញដូរមនុស្ស (អាចជាសកម្មភាព)
- រំលេចចំណុចពាក់ព័ន្ធនឹងគោលការណ៍មិនដាក់ទោសជនរងគ្រោះ ដែលត្រូវបានបង្ខំឱ្យប្រព្រឹត្តិបទល្មើស
- ច្បាប់ពពោះជំនួស ច្បាប់ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ច្បាប់ពាក់ព័ន្ធ

ជាទីបញ្ចប់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិក សមាជិកា នៃអង្គពិធីទាំងមូល ដែលបានចំណាយពេលមកចូលរួមសិក្ខាសាលាស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល៥ឆ្នាំ (២០២៤-២០២៨) នាពេលនេះ និងបានជូនពរសមាជិក សមាជិកា នៃអង្គពិធីទាំងមូល សូមទទួលបានជោគជ័យគ្រប់ភារកិច្ច។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃ សុក្រ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ មីនា ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក **អ៊ុច ចាន់ធា**

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃពុធ ៤ កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ មីនា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ

15/03/24

ជូ_ប៊ុនអេង